ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ទីស្តីការគណៈរដ្ឋមន្ត្រី
លេខ: ៨៨ ស.ស.ណ

ថ្ងៃសុក្រ ៤រោច ខែបុស្ស ឆ្នាំរោង ឆស័ក ព.ស.២៥៦៨
រាជធានីភ្នំពេញ ថ្ងៃទី១៧ ខែមករា ឆ្នាំ២០២៥

**ឧបនាយករដ្ឋមន្ត្រីប្រចាំការ រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី**
**សូមជម្រាបជូន**

- **ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ**
- **ឯកឧត្តមឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមុខងារសាធារណៈ**
- **ឯកឧត្តមរដ្ឋមន្ត្រីក្រសួងអធិការកិច្ច**

**កម្មវត្ថុ៖** ករណីការស្នើសុំពិនិត្យនិងសម្រេចលើគោលការណ៍បន្ថែម ដើម្បីអនុវត្តគោលការណ៍គន្លឹះទាំង៥ របស់រាជរដ្ឋាភិបាលសម្រាប់ការរៀបចំក្របខ័ណ្ឌ និងវិធាននៃប្រព័ន្ធសវនកម្មផ្ទៃក្នុង និងអធិការកិច្ចរបស់រាជរដ្ឋាភិបាល។

**យោង ៖** - លិខិតលេខ១០៥២១ សហវ.ល.ស.អ ចុះថ្ងៃទី២៣ ខែកញ្ញា ឆ្នាំ២០២៤ របស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- លិខិតលេខ២៣៩ សហវ.ល.ស.អ ចុះថ្ងៃទី១៥ ខែមករា ឆ្នាំ២០២៥របស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- ចំណារដ៏ខ្ពង់ខ្ពស់បំផុតរបស់សម្តេចមហាបវរធិបតី **ហ៊ុន ម៉ាណែត** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី៣ ខែមករា ឆ្នាំ២០២៥។

សេចក្តីដូចមានចែងក្នុងកម្មវត្ថុនិងយោងខាងលើ ទីស្តីការគណៈរដ្ឋមន្ត្រីសូមជម្រាបជូនឯកឧត្តមជ្រាបថា រាជរដ្ឋាភិបាលសម្រេចលើគោលការណ៍បន្ថែម ដើម្បីអនុវត្តគោលការណ៍គន្លឹះទាំង៥ របស់រាជរដ្ឋាភិបាលសម្រាប់ការរៀបចំក្របខ័ណ្ឌ និងវិធាននៃប្រព័ន្ធសវនកម្មផ្ទៃក្នុង និងអធិការកិច្ចរបស់រាជរដ្ឋាភិបាល និងសេចក្តីព្រាងច្បាប់ស្តីពីអធិការកិច្ច ដូចខាងក្រោម៖

១- ក្រសួងដែលអគ្គាធិការដ្ឋាន/អធិការដ្ឋាន/អង្គភាពជំនាញផ្សេងទៀត មានសមត្ថកិច្ចធ្វើអធិការកិច្ចនៅអង្គភាពខាងក្រៅ (អង្គភាពដែលមិនស្ថិតក្រោមរចនាសម្ព័ន្ធក្រសួង ស្ថាប័នសាមី) តាមវិស័យជំនាញដែលក្រសួង ឬស្ថាប័នសាមីទទួលបន្ទុកដែលច្បាប់បានកំណត់ ត្រូវបន្តអនុវត្តភារកិច្ចរបស់ខ្លួនអនុលោមតាមច្បាប់ និងលិខិតបទដ្ឋានគតិយុត្តជាធរមាន ប៉ុន្តែត្រូវកំណត់យន្តការសហការរវាងអង្គភាពពាក់ព័ន្ធ ដោយត្រូវចុះទៅតែមួយលើក ចំពោះករណីធ្វើអធិការកិច្ចនៅគោលដៅតែមួយ និងក្នុងការិយបរិច្ឆេទតែមួយ ទោះបីមានកម្មវត្ថុផ្សេងគ្នាក៏ដោយ។ ទន្ទឹមនេះ ក្រសួង ស្ថាប័នសាមី ត្រូវបែងចែកមុខងារឱ្យបានច្បាស់លាស់រវាងការត្រួតពិនិត្យ

អង្គភាពផ្ទៃក្នុង ដែលត្រូវអនុវត្តដោយអង្គភាពសវនកម្មផ្ទៃក្នុង និងការត្រួតពិនិត្យផ្ទៃក្រៅ ដែលត្រូវអនុវត្តដោយអគ្គាធិការដ្ឋាន/អធិការដ្ឋាន/អង្គភាពជំនាញផ្សេងទៀត ស្របពេលដែលរាជរដ្ឋាភិបាលកំពុងណែនាំឱ្យក្រសួង ស្ថាប័ន ពិនិត្យ វិភាគមុខងារ និងរចនាសម្ព័ន្ធរបស់ខ្លួនឡើងវិញ។

ក្រសួង ស្ថាប័ន ដែលមានសមត្ថកិច្ចធ្វើអធិការកិច្ចតាមវិស័យជំនាញរបស់ក្រសួង ឬស្ថាប័នសាមីទទួលបន្ទុក នៅអង្គភាពខាងក្រៅតាមច្បាប់កំណត់ ត្រូវរៀបចំវិធាននិងនីតិវិធីប្រតិបត្តិ (Standard Operating Procedure-SOP) នៃអភិក្រមធ្វើអធិការកិច្ច ដើម្បីអនុវត្តឱ្យបានច្បាស់លាស់។

២- ក្រសួង ស្ថាប័នដែលអគ្គាធិការដ្ឋាន/អធិការដ្ឋានពុំមានសមត្ថកិច្ច ធ្វើអធិការកិច្ចតាមវិស័យជំនាញរបស់ក្រសួង ឬស្ថាប័នសាមីទទួលបន្ទុកនៅអង្គភាពខាងក្រៅ ក្រសួង ស្ថាប័ននោះ ត្រូវធ្វើសមាហរណកម្មភារកិច្ចអគ្គាធិការដ្ឋាន/អធិការដ្ឋាន បញ្ចូលគ្នាជាមួយអង្គភាពសវនកម្មផ្ទៃក្នុងរបស់ក្រសួង ស្ថាប័ន និងត្រូវរៀបចំដូចខាងក្រោម៖

- ក្រសួងដែលមានរចនាសម្ព័ន្ធជាអគ្គាធិការដ្ឋាន (កម្រិតអគ្គនាយកដ្ឋាន) ត្រូវកំណត់អង្គភាពសវនកម្មផ្ទៃក្នុង កម្រិតជាអគ្គនាយកដ្ឋាន
- ក្រសួងដែលមានរចនាសម្ព័ន្ធជាអធិការដ្ឋាន (កម្រិតនាយកដ្ឋាន) ជាកម្មវត្ថុក្នុងការពិគ្រោះយោបល់ជាមួយក្រសួងមុខងារសាធារណៈ ដើម្បីកំណត់កម្រិតអង្គភាពសវនកម្មផ្ទៃក្នុង ជានាយកដ្ឋាន ឬអគ្គនាយកដ្ឋាន។ គួរព្យាយាមកុំដំឡើងកម្រិត លើកលែងតែករណីចាំបាច់បំផុតដែលទំហំការងារទាមទារឱ្យដំឡើងកម្រិតជាអគ្គនាយកដ្ឋាន។ ក្នុងករណីនេះ ត្រូវស្នើសុំការសម្រេចដោយផ្អែកលើមូលហេតុច្បាស់លាស់។

៣- ក្រសួងអធិការកិច្ច ជាអធិការកិច្ចរាជរដ្ឋាភិបាល មានភារកិច្ច ដូចខាងក្រោម៖

- ធ្វើអធិការកិច្ចលើគ្រប់វិស័យដោយផ្អែកតាមអភិក្រមចំនួន៧ ដូចមានកំណត់នៅក្នុងអនុក្រឹត្យលេខ ១៦៨ អនក្រ.បក ចុះថ្ងៃទី៨ ខែតុលា ឆ្នាំ២០២០ ស្តីពីក្របខ័ណ្ឌមុខងារ ភារកិច្ចរបស់សវនកម្មផ្ទៃក្នុង និងអធិការកិច្ច និងលិខិតលេខ៦៥៦ សជណ ចុះថ្ងៃទី១៧ ខែឧសភា ឆ្នាំ២០២៤ របស់ទីស្តីការគណៈរដ្ឋមន្ត្រី ដែលក្នុងនោះ អភិក្រមចំនួន៦ ត្រូវមានវិធាននិងនីតិវិធីប្រតិបត្តិ (SOP) ច្បាស់លាស់ លើកលែងតែការចុះធ្វើអធិការកិច្ចតាមបញ្ជារបស់ប្រមុខរាជរដ្ឋាភិបាល
- ការតាមដានការអនុវត្តច្បាប់និងមុខងាររបស់ក្រសួង ស្ថាប័នរបស់រាជរដ្ឋាភិបាល ត្រូវមានអភិក្រម និងវិធាននិងនីតិវិធីប្រតិបត្តិ (SOP) ច្បាស់លាស់
- ការទទួល និងដោះស្រាយបណ្តឹងតវ៉ា និងបណ្តឹងបរិហារក្នុងសមត្ថកិច្ចរបស់រាជរដ្ឋាភិបាល ត្រូវមានអភិក្រម និងវិធាននិងនីតិវិធីប្រតិបត្តិ (SOP) ច្បាស់លាស់
- ការរៀបចំត្រូវឱ្យស្របទៅនឹងតួនាទី ភារកិច្ចរបស់ក្រសួងដែលកំពុងរៀបចំថ្មី។

៤- ក្រសួងអធិការកិច្ច ពុំត្រូវចុះធ្វើអធិការកិច្ចនៅក្រសួងការពារជាតិ និងក្រសួងមហាផ្ទៃ លើកលែងតែមានបញ្ជារបស់ប្រមុខរាជរដ្ឋាភិបាល ដោយឡែកការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ដែលមិនពាក់ព័ន្ធនឹងកិច្ចការសន្តិសុខជាតិ ការសម្ងាត់ជាតិ ឬបច្ចេកទេសកងកម្លាំងប្រដាប់អាវុធ ជាកម្មវត្ថុនៃការធ្វើអធិការកិច្ចហិរញ្ញវត្ថុដោយក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។

៥- ធ្វើវិសោធនកម្មអនុក្រឹត្យលេខ១០៨ អនក្រ.បក ចុះថ្ងៃទី១ ខែមិថុនា ឆ្នាំ២០២២ ស្ដីពីវិធាននិងនីតិវិធីនៃការធ្វើអធិការកិច្ចហិរញ្ញវត្ថុ ដើម្បីមានសង្គតិភាពនឹងច្បាប់ស្ដីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈឆ្នាំ២០២៣ ក្នុងការកំណត់អភិក្រមនៃការធ្វើអធិការកិច្ចហិរញ្ញវត្ថុ យន្តការទទួលនិងដោះស្រាយបណ្ដឹងនានាលើលទ្ធផលអធិការកិច្ចហិរញ្ញវត្ថុ និងជាមូលដ្ឋានកំណត់នូវវិធាននិងនីតិវិធីប្រតិបត្តិ (SOP) ក្នុងការធ្វើអធិការកិច្ចឱ្យបានច្បាស់លាស់។

៦- ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ត្រូវយកគោលការណ៍គន្លឹះបន្ថែមទាំងនេះ ទៅចាត់ចែងរៀបចំការងារលម្អិតបន្តជាមួយក្រសួង ស្ថាប័ន ដោយមានការចូលរួមរបស់ក្រសួងមុខងារសាធារណៈ និងក្រសួងអធិការកិច្ច ដើម្បីអនុវត្តឱ្យមានប្រសិទ្ធភាព។

សេចក្ដីដូចបានជម្រាបជូនខាងលើ សូមឯកឧត្តមជ្រាបនិងចាត់ចែងអនុវត្ត។

**ជ.រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី**
**រដ្ឋលេខាធិការប្រចាំការ**

បណ្ឌិតសភាចារ្យ **ហ៊ីង ថូរ៉ាក់ស៊ី**

**ចម្លងជូន៖**
- គ្រប់ក្រសួង ស្ថាប័ន
- អាជ្ញាធរសេវនកម្មជាតិ
- ខុទ្ទកាល័យសម្ដេចមហាបវរធិបតីនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឯកឧត្តមឧបនាយករដ្ឋមន្ត្រីប្រចាំការ
- ឯកសារ កាលប្បវត្តិ